**សាលាដំបូងខេត្តកណ្ដាល**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# តាងនាមប្រជារាស្ត្រខ្មែរ

សំណុំរឿងព្រហ្មទណ្ឌលេខ០៨៤ អ.ក
ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦
សាលក្រមលេខ១២០(ឈ)
ចុះថ្ងៃទី១៨ខែកក្កដា ឆ្នាំ២០១៦

សាលាដំបូងខេត្តកណ្ដាលបានបើកសវនាការជំនុំជម្រះជាសាធារណៈនាថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ដោយមានសមាសភាពដូចតទៅ

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

**ដើម្បីជំនុំជម្រះ**

សំណុំរឿងព្រហ្មទណ្ឌលេខ៖ ០៨៤ អ.ក ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦ ដែលមានជនជាប់ចោទ ៖

ឈ្មោះ[redacted] វណ្ណៈ ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីកន្លែងកំណើតភូមិកាព្រហ្ម ឃុំព្រែកឯង ស្រុកកៀនស្វាយ ខេត្តកណ្ដាល ទីលំនៅបច្ចុប្បន្នភូ[redacted] អំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន ០២ នាក់ (ឃុំខ្លួន)។

ជាប់ចោទពីបទ ៖ អំពើលួច ប្រព្រឹត្តនៅភូមិស្ដៅកន្លែង៣ ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ។

- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ៣៩៨ ដកសព ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦។
- បានឃើញ ដីកាដំណោះស្រាយលេខ ៖ ៦០៨ ដកដស ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦។
- បានឃើញ សំណុំរឿងជំនុំជម្រះលេខ ៖ ៨៤០ ជរ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៦។
- បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ៨៤៨ ដកចត/១៦ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៦។

**អង្គហេតុមានដូចតទៅ**

កាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦ ម៉ោង០៨និង៣០នាទី ឈ្មោះ [redacted] វណ្ណៈ ភេទប្រុស អាយុ ២១ ឆ្នាំ បានជិះម៉ូតូមួយគ្រឿងម៉ាក សេ១២៥ ពាក់ស្លាកលេខ ភ្នំពេញ 1G-4412 ម្នាក់ឯងចេញពីផ្ទះទៅលេងផ្ទះបងប្អូនឈ្មោះ [redacted] សុខឡែន ភេទស្រី អាយុ១៧ ឆ្នាំ មានទីលំនៅភូមិឈើកាច់ ស្រុកបាភ្នំ ខេត្តព្រៃវែង លុះជិះមកដល់ផ្ទះ [redacted] ស្រីម៉ុច ភេទស្រី អាយុ២៣ ឆ្នាំ មុខរបរលក់ដូរ ឈ្មោះ [redacted] វណ្ណៈ ក៏បានឈប់ម៉ូតូទិញទឹកសុទ្ធមួយដប ពីឈ្មោះ [redacted] ស្រីម៉ុច ពេលទិញហើយក៏អង្គុយផឹកលើម៉ូតូ ហើយឈ្មោះ [redacted] ស្រីម៉ុច ចូលទៅក្នុងផ្ទះ ពេលនោះឈ្មោះ [redacted] វណ្ណៈ ក៏បានធ្វើសកម្មភាពលួចស្រាបៀរអង្គរកំប៉ុងចំនួន០៨ កេស ដាក់លើម៉ូតូបម្រុងជិះគេចខ្លួន។ ពេលនោះឈ្មោះ [redacted] ស្រីម៉ុច បានដើរចេញពីផ្ទះ ក៏ស្ទុះចាប់ទាញម៉ូតូរបស់ឈ្មោះ [redacted] វណ្ណៈ ពីក្រោយប៉ុន្តែទាញពុំឈ្នះ ហើយបានស្រែកថាចោរៗ ឃើញដូច្នេះ ឈ្មោះ យក្ស ភេទប្រុស អាយុ៣០ ឆ្នាំ បានជិះម៉ូតូដេញពីក្រោយទើបឃាត់ខ្លួនឈ្មោះ [redacted] វណ្ណៈ ប្រគល់ឲ្យកម្លាំងនគរបាលប៉ុស្តិ៍ដីឥដ្ឋ។

Scanned by CamScanner

## <u>នាពេលសវនាការ</u>

- ដើមបណ្ដឹងរដ្ឋប្បវេណី ឈ្មោះ[redacted]ស្រីម៉ុច ភេទស្រី អាយុ២៣ ឆ្នាំ បានឆ្លើយថា នៅថ្ងៃទី ១៣ ខែមករា ឆ្នាំ ២០១៦ វេលាម៉ោង ១០និង១០នាទី ខ្លួនកំពុងអង្គុយលក់អីវ៉ាន់នៅផ្ទះ ស្រាប់តែមានមនុស្សប្រុសម្នាក់ឈ្មោះ [redacted] វណ្ណៈ ជិះម៉ូតូមកទិញទឹកសុទ្ធមួយដប រួចហើយធ្វើសកម្មភាពលួចយកស្រាបៀរអង្គរកំប៉ុងរបស់ខ្លួនចំនួន ០៤ កេសដែលខ្លួនដាក់លក់ជិះគេចខ្លួន ខ្លួនមិនទាមទារសំណងអ្វីទេ ខ្លួនសុំតែស្រាបៀររបស់ខ្លួនវិញ។

- អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ស៊ីថាន ភេទប្រុស អាយុ៣១ ឆ្នាំ បានឆ្លើយថា មុនពេលកើតហេតុ ខ្លួនបានជិះម៉ូតូតាមបណ្ដោយផ្លូវជាតិលេខ១ពីលិចទៅកើតចំងាយប្រហែល ៥០ ម៉ែត្រ ខ្លួនបានឃើញមនុស្សស្រីម្នាក់បានចាប់ទាញម៉ូតូ តែទាញម៉ូតូនោះមិនជាប់ ម៉ូតូនោះក៏បានចេញទៅ បន្ទាប់មកខ្លួនមកកន្លែងកើតហេតុ មានអ្នកជិតខាងស្បែរនោះ ស្រែកថាចោរៗ ភ្លាមនោះខ្លួនក៏បានជិះម៉ូតូដេញតាមចោរនោះប្រហែល២គីឡូម៉ែត្រ ក៏ឃាត់បានចោរ ព្រមទាំងវត្ថុតាងទាំងម៉ូតូទាំងមនុស្ស រួចហើយក៏បានទូរស័ព្ទហៅកងកម្លាំងសមត្ថកិច្ចប៉ុស្តិ៍ដីឥដ្ឋ ពេលសមត្ថកិច្ចមកដល់ ខ្លួនប្រគល់ជនល្មើសរួមជាមួយម៉ូតូ និងវត្ថុតាងឲ្យទៅសមត្ថកិច្ច រួចហើយខ្លួនត្រឡប់មកផ្ទះវិញ។

- ជនជាប់ចោទឈ្មោះ [redacted] វណ្ណ បានឆ្លើយថា សមត្ថកិច្ចបានឃាត់ខ្លួន ខ្លួននៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦ នៅថ្ងៃកើតហេតុខ្លួនបានជិះម៉ូតូម៉ាកហុងដា សេ១២៥ ជាកម្មសិទ្ធរបស់ខ្លួន ទៅលួចស្រាបៀររបស់គេ លួចបានចំនួន ០៤ កេស លើកដាក់ម៉ូតូជិះចេញបានប្រហែល១គីឡូដី ស្រាប់តែម្ចាស់គេទាន់ ចាប់ខ្លួនបានប្រគល់ឲ្យទៅសមត្ថកិច្ច។ ពេលទៅលួច ខ្លួនបានជិះម៉ូតូចេញទៅតែម្នាក់ឯងទេ ហើយខ្លួនទើបតែលួចលើកទីមួយទេ។

- តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា: ផ្អែកតាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី សាក្សី ជនជាប់ចោទ របាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងវត្ថុតាងដែលប្រមូលបាន មានភាពស៊ីសង្វាក់គ្នា បញ្ជាក់បានថានៅថ្ងៃកើតហេតុជនជាប់ចោទពិតបានលួចស្រាបៀររបស់ជនរងគ្រោះប្រាកដមែន ដូចនេះតំណាងអយ្យការនៅតែរក្សាការចោទប្រកាន់លើឈ្មោះ[redacted]វណ្ណៈ ភេទប្រុស អាយុ ២១ ឆ្នាំ ពីបទៈ លួច ប្រព្រឹត្តនៅភូមិស្ពៅកន្លែង៣ ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីថ្ងៃទី ១៣ ខែមករា ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ តាមដីកាសន្និដ្ឋានស្ថាពរលេខ៣៩៨ ដកសព ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ទុកជាបានការនៅដដែល និងស្នើសុំផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់។

- ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី
- ក្រោយពីបានស្ដាប់អំណានចម្លើយរបស់សាក្សី
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## <u>យល់ឃើញថា</u>

១ តាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី សាក្សី ជនជាប់ចោទ របាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងវត្ថុតាងដែលប្រមូលបាន មានភាពស៊ីសង្វាក់គ្នា ដែលអាចឲ្យតុលាការជឿបានថា ជនជាប់ចោទឈ្មោះ[redacted]វណ្ណៈ ពិតជាបានលួចស្រាបៀររបស់ឈ្មោះ[redacted]ស្រីម៉ុច ប្រាកដមែន គប្បីតុលាការធ្វើការពិចារណាអង្គហេតុ និងលទ្ធផលដែលជនជាប់ចោទបានប្រព្រឹត្ត។

២ ជនជាប់ចោទឈ្មោះ [redacted]វណ្ណៈ បានលួចស្រាបៀររបស់ឈ្មោះ [redacted] ស្រីម៉ុច ដែលអំពើនេះច្បាប់ចាត់ទុកថាជា អំពើលួច តាមបញ្ញាតិមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ។

Scanned by CamScanner

៣ តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា: ផ្អែកតាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី សាក្សី ជនជាប់ចោទ របាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងវត្ថុតាងដែលប្រមូលបាន មានភាពស៊ីសង្វាក់គ្នា បញ្ជាក់បានថានៅថ្ងៃកើតហេតុជនជាប់ចោទពិតបានលួចស្រាបៀររបស់ជនរងគ្រោះប្រាកដមែន ដូចនេះតំណាងអយ្យការនៅតែរក្សាការចោទប្រកាន់លើឈ្មោះ [redacted] វណ្ណៈ ភេទប្រុស អាយុ ២១ ឆ្នាំ ពីបទ៖ លួច ប្រព្រឹត្តនៅភូមិស្ពានក្តៅ ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីថ្ងៃទី ១៣ ខែមករា ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ តាមដីកាសន្និដ្ឋានស្ថាពរលេខ៣៩៨ ដកសព ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ទុកជាបានការនៅដដែល និងស្នើសុំផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់។

៤ ពេលប្រព្រឹត្តបទល្មើសជនជាប់ចោទ ជានីតិជន មានស្មារតីគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវនូវអំពើល្មើសច្បាប់ដែលខ្លួនបានប្រព្រឹត្ត ហើយមានចេតនាពិតប្រាកដ ក្នុងការប្រព្រឹត្តអំពើលួច។

៥ អំពើរបស់ជនជាប់ចោទ ធ្វើឲ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់អ្នកដទៃ សន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយរបស់សង្គម។

៦ មានភស្តុតាង និងធាតុផ្សំដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ ភេទប្រុស អាយុ២១ឆ្នាំ ពីបទ៖ លួច ប្រព្រឹត្តនៅភូមិស្ពានក្តៅ ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ។

៧ វត្ថុតាងរួមមាន៖ ស្រាបៀរអង្គរ ០៤ កេស និង ម៉ូតូ ០១ មួយគ្រឿង ម៉ាក C 125 ពាក់ស្លាកលេខ ភ្នំពេញ 1G-4412 គប្បីប្រគល់ឲ្យម្ចាស់ដើមវិញ។

**ហេតុដូច្នេះសម្រេច**

១ ផ្ដន្ទាទោសលើឈ្មោះ [redacted] វណ្ណៈ ភេទប្រុស អាយុ២១ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន០៧ ខែ ពីបទ៖លួច ប្រព្រឹត្តនៅភូមិស្ពានក្តៅ ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ។

២ វត្ថុតាងរួមមាន៖

ក. ស្រាបៀរអង្គរ ០៤ កេស ត្រូវប្រគល់ឲ្យម្ចាស់ដើមវិញ

ខ. ម៉ូតូ ០១ មួយគ្រឿង ម៉ាក C 125 ពាក់ស្លាកលេខ ភ្នំពេញ 1G-4412 ប្រគល់ឲ្យម្ចាស់ដើមវិញ។

៣ សាលាក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ចំពោះមុខជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី។

- ទុកសិទ្ធិប្ដឹងតវ៉ាតាមកំណត់ច្បាប់។

ក្រឡាបញ្ជីសវនាការ

[redacted]

ចៅក្រមជំនុំជម្រះ

[redacted]

Scanned by CamScanner